**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខៈ ២៤៣៩ មស.ឧក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**សូមគោរពជូន**
**សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ**
**នៃក្រសួង ស្ថាប័ន**

**កម្មវត្ថុ** : ផ្ដល់ជូនតារាងគំរូសម្រាប់រៀបចំចងក្រងរចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៅតាមមុខតំណែងគ្រប់គ្រង។

**យោង** : អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ មានកិត្តិយសសូមគោរពជម្រាបជូន សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ មេត្តាជ្រាបថា អនុលោមមាត្រា១៨ នៃអនុក្រឹត្យដូចមានយោងខាងលើ ចែងថា «ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ខែ ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវរៀបចំចងក្រងរចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៅតាមមុខតំណែងគ្រប់គ្រង ផ្ដល់មកក្រសួងមុខងារសាធារណៈ ឱ្យបានរួចរាល់ផ្អែកលើតារាងគំរូផ្ដល់ដោយក្រសួងមុខងារសាធារណៈ ព្រមទាំងត្រូវចាត់ចែងណែនាំដល់អង្គភាពក្រោមឱវាទនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យរៀបចំបែងចែកភារកិច្ចទៅតាមមុខតំណែងនិងភារកិច្ចដល់មន្ត្រីរាជការគ្រប់រូបនៃអង្គភាពរបស់ខ្លួនឱ្យបានច្បាស់លាស់និងរួចរាល់ ដើម្បីកំណត់បន្ទាត់គណនេយ្យភាពនិងការទទួលខុសត្រូវរបស់មន្ត្រីរាជការស៊ីវិលម្នាក់ៗក្នុងការបំពេញមុខងាររបស់ខ្លួន»។ ដើម្បីចូលរួមអនុវត្តខ្លឹមសារនៃអនុក្រឹត្យនេះឱ្យទាន់ការកំណត់ ក្រសួងមុខងារសាធារណៈ សូមស្នើសុំ សម្ដេច ឯកឧត្ដម លោកជំទាវ សហការរៀបចំបំពេញទិន្នន័យទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិនិងបញ្ជូនមកក្រសួងមុខងារសាធារណៈ ឱ្យបានទាន់ពេលវេលាស្របតាមការកំណត់ក្នុងអនុក្រឹត្យដូចយោងខាងលើ តាមតារាងគំរូដូចបានគោរពជូនភ្ជាប់ជាមួយស្រាប់ទាំង Soft Copy ទាំង Hard Copy។ ចំពោះតារាងគំរូនេះជា Soft Copy មានដាក់ជូនក្នុងគេហទំព័រក្រសួងមុខងារសាធារណៈ www.mcs.gov.kh/files/position.docx។ ចំពោះក្រសួងមហាផ្ទៃ សូមមេត្តាចាត់ចែងឱ្យសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបំពេញតាមតារាងគំរូនេះ ផ្ដល់ជូនក្រសួងមុខងារសាធារណៈតាមការគួរ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូមសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ មេត្តាជ្រាបនិងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ចម្លងជូន**:
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

**ពេជ្រ ប៊ុនធិន**

**តារាងគំរូ**

# តារាង
# ស្តីពី
# រចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៃក្រសួង ស្ថាប័ន......................................(សម្រាប់ថ្នាក់ជាតិ)

| **ល.រ** | **អង្គភាព** | | | | **មុខតំណែង ចំនួនមុខតំណែងជាក់ស្តែង[១] និងចំនួនមន្ត្រី** | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | អគ្គនាយក | អគ្គនាយករង | ប្រធាន នាយកដ្ឋាន | អនុប្រធាន នាយកដ្ឋាន | ប្រធាន ការិយាល័យ | អនុប្រធាន ការិយាល័យ | ថ្នាក់ក្រោម ការិយាល័យ (ប្រធាននិង អនុប្រធាន) | មន្ត្រី | ផ្សេងៗ |
| ១ | អគ្គនាយកដ្ឋាន... | | | | | | | | | | | | |
| | ១.១ | នាយកដ្ឋាន... | | | | | | | | | | | |
| | | ១.១.១ | ការិយាល័យ... | | | | | | | | | | |
| | | ១.១.២ | ការិយាល័យ... | | | | | | | | | | |
| | | | ១.១.១.១ | អង្គភាពថ្នាក់ក្រោម ការិយាល័យ... | | | | | | | | | |

**កំណត់សម្គាល់:**

[១] ចំនួនមុខតំណែងជាក់ស្តែង សំដៅដល់មុខតំណែងដែលមានការតែងតាំងជាផ្លូវការរួចហើយ។ ប្រសិនបើមិនទាន់មានការតែងតាំងត្រូវទុកចំហរ។

- លេខមួយខ្ទង់សម្រាប់សម្គាល់អង្គភាពថ្នាក់ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន ឬប្រហាក់ប្រហែល ដោយរួមបញ្ចូលជាអាទិ៍ សាកលវិទ្យាល័យ វិទ្យាស្ថាន មជ្ឈមណ្ឌល គ្រឹះស្ថានសាធារណៈរដ្ឋបាល
- លេខពីរខ្ទង់សម្រាប់សម្គាល់អង្គភាពថ្នាក់នាយកដ្ឋាន ឬប្រហាក់ប្រហែល ដោយរួមបញ្ចូលជាអាទិ៍ មហាវិទ្យាល័យ វិទ្យាស្ថាន មជ្ឈមណ្ឌល គ្រឹះស្ថានសាធារណៈរដ្ឋបាល
- លេខបីខ្ទង់សម្រាប់សម្គាល់អង្គភាពថ្នាក់ការិយាល័យឬប្រហាក់ប្រហែលដោយរួមបញ្ចូលជាអាទិ៍ វិទ្យាស្ថាន មជ្ឈមណ្ឌល គ្រឹះស្ថានសាធារណៈរដ្ឋបាល
- លេខបួនខ្ទង់សម្រាប់សម្គាល់អង្គភាពថ្នាក់ក្រោមការិយាល័យ។

**តារាងគំរូ**

**តារាង**
**ស្តីពី**
**រចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៃមន្ទីរ....................................... (សម្រាប់ថ្នាក់ក្រោមជាតិ)**

| **ល.រ** | **អង្គភាព** | | **មុខតំណែង ចំនួនមុខតំណែងជាក់ស្តែង[១] និងចំនួនមន្ត្រី** | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ប្រធានមន្ទីរ | អនុប្រធានមន្ទីរ | ប្រធាន ការិយាល័យ | អនុប្រធាន ការិយាល័យ | មន្ត្រី | ផ្សេងៗ |
| ១ | មន្ទីរ.../អង្គភាពថ្នាក់ប្រហាក់ប្រហែល... | | | | | | | |
| | ១.១ | ការិយាល័យ.../អង្គភាពថ្នាក់ប្រហាក់ប្រហែល... | | | | | | |

**កំណត់សម្គាល់:**

[១] ចំនួនមុខតំណែងជាក់ស្តែង សំដៅដល់មុខតំណែងដែលមានការតែងតាំងជាផ្លូវការរួចហើយ។ ប្រសិនបើមិនទាន់មានការតែងតាំងត្រូវទុកចំហរ។

**តារាងគំរូ**

**តារាង**
**ស្តីពី**
**រចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៃសាលារាជធានី ខេត្ត**.......................................

<table>
<tr><th rowspan="2">ល.រ</th><th rowspan="2" colspan="4">អង្គភាព</th><th colspan="11">មុខតំណែង ចំនួនមុខតំណែងជាក់ស្តែង[១] និងចំនួនមន្ត្រី</th></tr>
<tr><th>អភិបាល</th><th>អភិបាលរង</th><th>នាយករដ្ឋបាល</th><th>នាយករងរដ្ឋបាល</th><th>នាយកទីចាត់ការ</th><th>នាយករងទីចាត់ការ</th><th>ប្រធានការិយាល័យ</th><th>អនុប្រធានការិយាល័យ</th><th>ថ្នាក់ក្រោមការិយាល័យ (ប្រធាននិងអនុប្រធាន)</th><th>មន្ត្រី</th><th>ផ្សេងៗ</th></tr>
<tr><td>១</td><td colspan="4">សាលារាជធានី ខេត្ត...</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td rowspan="4"></td><td>១.១</td><td colspan="3">ទីចាត់ការ..../អង្គភាពលទ្ធកម្ម....</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td rowspan="3"></td><td>១.១.១</td><td colspan="2">ការិយាល័យ...</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>១.១.២</td><td colspan="2">ការិយាល័យ...</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td>១.១.១.១</td><td>អង្គភាពថ្នាក់ក្រោមការិយាល័យ...</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
</table>

**កំណត់សម្គាល់:**

[១] ចំនួនមុខតំណែងជាក់ស្តែង សំដៅដល់មុខតំណែងដែលមានការតែងតាំងជាផ្លូវការរួចហើយ។ ប្រសិនបើមិនទាន់មានការតែងតាំងត្រូវទុកចំហរ។

**តារាងគំរូ**

**តារាង**

**ស្ដីពី**

**រចនាសម្ព័ន្ធគ្រប់គ្រង មុខតំណែងគ្រប់គ្រង និងចំនួនមន្ត្រីនៃសាលាក្រុង ស្រុក ខណ្ឌ**......................................

| ល.រ | អង្គភាព | | មុខតំណែង ចំនួនមុខតំណែងជាក់ស្ដែង[១] និងចំនួនមន្ត្រី | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | អភិបាល | អភិបាលរង | នាយករដ្ឋបាល | នាយករងរដ្ឋបាល | ប្រធានការិយាល័យ | អនុប្រធានការិយាល័យ | មន្ត្រី | ផ្សេងៗ |
| ១ | សាលាក្រុង ស្រុក ខណ្ឌ... | | | | | | | | | |
| | ១.១ | ការិយាល័យ..../អង្គភាពលទ្ធកម្ម.... | | | | | | | | |

**កំណត់សម្គាល់:**

[១] ចំនួនមុខតំណែងជាក់ស្ដែង សំដៅដល់មុខតំណែងដែលមានការតែងតាំងជាផ្លូវការរួចហើយ។ ប្រសិនបើមិនទាន់មានការតែងតាំងត្រូវទុកចំហរ។